# ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) ២០១៩-២០២៣

*សេចក្តីសង្ខេបនៃការពិភាក្សាពិគ្រោះយោបល់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩

<u>អ្នកចូលរួម៖</u> មានតំណាងចំនួន ៥រូប មកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

<u>សេចក្តីផ្តើម៖</u> ធនាគារពិភពលោកបើកកិច្ចពិគ្រោះយោបល់នេះដោយធ្វើការរៀបរាប់សង្ខេបពីអំពីបរិបទរបស់ប្រទេស និងអាទិភាពនានាក្នុងកិច្ចការអភិវឌ្ឍន៍ ដូចត្រូវបានរកឃើញតាមរយៈការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ (SCD) ព្រមទាំងសំណើវិស័យត្រូវផ្តោតយកចិត្តទុកដាក់សម្រាប់ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) ដែលស្របតាមអាទិភាពរបស់យុទ្ធសាស្ត្រចតុកោណនៃរាជរដ្ឋាភិបាលកម្ពុជា។ បណ្តាវិស័យត្រូវផ្តោតយកចិត្តទុកដាក់ក្នុងក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) រួមមាន៖ ១) លើកកម្ពស់ប្រសិទ្ធផលរបស់រដ្ឋ និងជំរុញការអភិវឌ្ឍវិស័យឯកជន, ២) ជំរុញការអភិវឌ្ឍមនុស្ស, ៣) កែលម្អវិស័យកសិកម្ម និងពង្រឹងការប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានធម្មជាតិឱ្យកាន់តែប្រសើរ និងមូលបទអន្តរវិស័យស្តីពីការពង្រឹងអភិបាលកិច្ច ស្ថាប័ន និងការចូលពាក់ព័ន្ធរបស់ពលរដ្ឋ។ បន្ថែមលើមាគ៌ាដែលត្រូវបានគ្រួសត្រាយដោយការវិនិច្ឆ័យស្ថានភាពប្រទេសមានលក្ខណៈជាប្រព័ន្ធ (SCD) និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល  ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា មានគោលដៅពិចារណាមើលអំពីឧត្តមភាពប្រៀបធៀបនៃវិស័យគម្រោងអនុវត្តនានារបស់ក្រុមធនាគារពិភពលោក។

<u>បញ្ហាធំៗដែលត្រូវបានលើកឡើងនៅក្នុងកិច្ចពិភាក្សាមាន៖</u> មូលធនមនុស្ស ការកសាងសមត្ថភាពវិស័យសាធារណៈ ការគ្រប់គ្រងបំណុល និង PPPs។

| វិស័យដែលត្រូវបានលើកយកមកពិភាក្សា | ចំណុចគោលសំខាន់ៗដែលបានលើកឡើង |
|---|---|
| **តើអ្វីខ្លះទៅជាបញ្ហា** | • ជារួម អាទិភាពនៃការអភិវឌ្ឍមាននៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដូច្នេះវាគឺជាវិធីសាស្ត្រត្រឹមត្រូវសម្រាប់ធនាគារ |

| | |
|---|---|
| ប្រឈមនិងភាពចាំបាច់បន្ទាន់ជាងគេនៅក្នុងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា? | ពិភពលោកប្រើដើម្បីជ្រើសយកអាទិភាពមួយចំនួនដើម្បីផ្តល់ការគាំទ្រ។ អ្នកចូលរួមកិច្ចពិភាក្សាបានយល់ស្របជាមួយអាទិភាពនិងវិស័យផ្តោតការយកចិត្តទុកដាក់ ដែលធនាគារពិភពលោកបានជ្រើសរើសយក។<br>• អ្នកចូលរួមបានគូសបញ្ជាក់ពីសារៈសំខាន់របស់មូលធនមនុស្ស ហើយបានពិភាក្សាគ្នាថារដ្ឋាភិបាលត្រូវធ្វើការសម្រេចចិត្តអំពីវិធីដ៏ល្អបំផុតដើម្បីផ្តល់ហិរញ្ញប្បទានគាំទ្រដល់គម្រោងនេះ (តាមរយៈថវិកាសាធារណៈ ឬជំនួយឥតសំណង)។ ជាទូទៅ ការកសាងសមត្ថភាពសម្រាប់ទាំងបុគ្គល និងស្ថាប័ន នឹងមានសារៈសំខាន់នៅឆ្នាំខាងមុខៗ ហើយទាំងនេះចាំបាច់ត្រូវមានអភិក្រមមួយដែលកាន់តែមានលក្ខណៈជាប្រព័ន្ធ និងបែបសមាហរណកម្មចូលគ្នាច្រើនឡើង។ |
| តើមានអ្វីខ្លះជាវិស័យអាទិភាពសម្រាប់ក្រុមធនាគារពិភពលោកបន្តជួយឧបត្ថម្ភនៅក្នុងអំឡុងពេល៥ឆ្នាំខាងមុខ? មានអ្វីខ្លះដែលក្រុមធនាគារពិភពលោកគួរបន្តសកម្មភាពជួយបន្ថែមទៀត ឬបន្ថយសកម្មភាពវិញ? | • អ្នកចូលរួមពិភាក្សាបានសង្កត់ធ្ងន់ថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចាត់ទុកតម្លៃបន្ថែមសំខាន់ៗរបស់ធនាគារពិភពលោកនៅក្នុងការផ្តល់ចំណេះដឹង ក្របខណ្ឌ និងឧបករណ៍ ជាជាងការផ្តល់ហិរញ្ញប្បទាន។ រដ្ឋាភិបាលសូមកោតសរសើរចំពោះការចែករំលែកបទពិសោធន៍នៃធនាគារពិភពលោកទាក់ទងនឹងការអភិវឌ្ឍ និងនិន្នាការសេដ្ឋកិច្ច នាពេលអនាគត។<br>• គម្រោងរបស់ធនាគារពិភពលោកនាពេលអនាគតគួរតែដាក់បញ្ចូលសេដ្ឋកិច្ចឌីជីថលធ្វើសមាសភាគបម្រុងមួយ មិនចាំបាច់ជាគម្រោងមួយដាច់ដោយឡែកនោះទេ ប៉ុន្តែជាការប្រើបច្ចេកវិជ្ជាឌីជីថល ឬបច្ចេវិជ្ជានវានុវត្តន៍ នៅពេលដែលអាចធ្វើទៅបានក្នុងប្រតិបត្តិការ ដើម្បីលើកទឹកចិត្តឱ្យមានកំណើនសេដ្ឋកិច្ចកម្រិតជឿនលឿនថែមទៀតរបស់ប្រទេសកម្ពុជា។<br>• ធនាគារពិភពលោកគួរតែពិភាក្សាបន្ថែមទៀតជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តី ពីការចូលពាក់ព័ន្ធជាមួយវិស័យឯកជន ដោយរដ្ឋាភិបាលទើបតែនឹងបានអនុម័តយុទ្ធសាស្រ្តភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន (PPPs) រួចហើយ។ ត្រង់នេះក៏ជាចំណុចល្អមួយដែរសម្រាប់ការចូលរួមរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)។<br>• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចង់ឃើញ IFC ធ្វើការក្នុងវិស័យជាច្រើន រួមទាំងវិស័យហិរញ្ញវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធ ផងដែរ។<br>• អ្នកចូលរួមបានលើកទឹកចិត្តធនាគារពិភពលោកឱ្យធ្វើការពិភាក្សាអំពីយុទ្ធសាស្រ្តគ្រប់គ្រងបំណុលជាមួយនាយកដ្ឋានពាក់ព័ន្ធ និងរិះរកមើលថាតើប្រធានបទនេះអាចមានលទ្ធភាពទទួលបានការគាំទ្រពីធនាគារដោយរបៀបណាខ្លះ ដូចជាតាមរយៈ ASAs នាពេលខាងមុខនេះ។<br>• ការចែករំលែកចំណេះដឹងរបស់ធនាគារពិភពលោកស្តីពីការផ្ទេរប្រាក់ និងការងារក្រៅប្រទេសរបស់ពលករកម្ពុជា នឹងត្រូវបានការសាទរវាយតម្លៃខ្ពស់។<br>• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាប់អារម្មណ៍ចង់មានគម្រោងមួយស្តីពីការអភិវឌ្ឍសន្តិសុខផ្នែកសុខភាពថ្នាក់ក្រោមជាតិ ប៉ុន្តែក៏ចង់ដឹងដែរអំពីប្រភពផ្តល់ហិរញ្ញប្បទានជាជំនួយឥតសំណង ដើម្បីស្វែងរកហិរញ្ញវត្ថុមកផ្គត់ផ្គង់គម្រោងនេះ។<br>• ធនាគារពិភពលោកគួរតែបន្តប្រើប្រាស់មេរៀនបទពិសោធន៍កន្លងមកអំពីពីបរិបទកម្ពុជាដើម្បីធ្វើការកែលម្អយុទ្ធសាស្រ្ត និងការអនុវត្តនាពេល |

| | |
|---|---|
| | អនាគត រួមមាន: ការរៀបចំគម្រោង លទ្ធកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុ។ |
| **តើមានអ្វីខ្លះដែលអាចជាបញ្ហាប្រឈមគួរឱ្យកត់សម្គាល់សម្រាប់ការអនុវត្ត ហើយថាតើបញ្ហាប្រឈមទាំងនោះអាចត្រូវបានកាត់បន្ថយដោយរបៀបណាខ្លះ?** | • នីតិវិធីលទ្ធកម្មរបស់ធនាគារពិភពលោកមានភាពស្មុគស្មាញ និងតម្រូវឱ្យរាជរដ្ឋាភិបាលត្រូវប្រើប្រាស់ធនធាននិងកិច្ចប្រឹងប្រែងច្រើន ដូច្នេះគួរតែសម្រួលនីតិវិធីទាំងនោះឱ្យសាមញ្ញបន្តិច តាមវិធីណាមួយដែលអាចធ្វើទៅបាន។<br>• ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនសូវបានសហការល្អជាមួយស្ថាប័ន IFC ទេក្នុងពេលកន្លងមក ដូច្នេះជាប្រការល្អដែលគួរតែមានការពង្រឹងទំនាក់ទំនង និងការសម្របសម្រួលការងារជាមួយគ្នានាពេលអនាគត។<br>• ជារឿយៗ ការផ្ទេរធនធានទៅឱ្យថ្នាក់ក្រោមតែងមានភាពយឺតយ៉ាវ ហើយរាជរដ្ឋាភិបាលត្រូវការធ្វើកិច្ចការនេះ។ រដ្ឋាភិបាលព្រួយបារម្ភថាគម្រោងដែលផ្តល់ជំនួយសម្បទានថវិកា Seed Grants តាមរយៈក្រុមប្រឹក្សាឃុំមិនមាននិរន្តរភាពទេ ពីព្រោះរដ្ឋាភិបាលថ្នាក់ក្រោមជាតិនឹងមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីបន្តការងារបានទេ បន្ទាប់ពីគម្រោងបានបញ្ចប់។<br>• ជាបញ្ហាប្រឈមមួយក្នុងការធ្វើការជាមួយដៃគូអភិវឌ្ឍន៍ នៅពេលដែលគម្រោងទាំងនោះមិនអាចរក្សាឱ្យមានអត្ថិភាពបន្តទៅមុខបាន បន្ទាប់ពីវាត្រូវបានបិទ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចង់ឱ្យរាជរដ្ឋាភិបាលមានភាពម្ចាស់ការជាងមុននៅលើគម្រោង ដើម្បីឱ្យវាមាននិរន្តរភាពបន្ថែមទៀតបន្ទាប់ពីវាចប់តាមកាលកំណត់។ វាគួរតែមានការផ្ទេរគម្រោងនេះទៅឱ្យរដ្ឋាភិបាល ជាជាងការគ្រាន់តែធ្វើអន្តរាគមន៍មួយរយៈកាល ហើយចប់បិទតែម្តង។<br>• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានពិភាក្សាលើប្រភេទមូលនិធិសម្រាប់រៀបចំប្រែក្លាយសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានលក្ខណៈស្ថាប័ន និងដើម្បីលើកកម្ពស់គណនេយ្យភាពរបស់ក្រុមប្រឹក្សាឃុំសង្កាត់។ ការណ៍នេះអាចជួយដល់អាណត្តិថ្នាក់ក្រោមជាតិឱ្យមានអភិបាលកិច្ចកាន់តែប្រសើរ និងការគ្រប់គ្រងកាន់តែស្វាហាប់ជាងនេះ។ |
| **អត្ថាធិប្បាយផ្សេងៗទៀត** | • អ្នកចូលរួមកិច្ចពិគ្រោះយោបល់បានលើកឡើងថានេះជាពេលវេលាដ៏ល្អសម្រាប់ការចូលពាក់ព័ន្ធរបស់ CPF និងដើម្បីពង្រឹងភាពជាដៃគូជាមួយធនាគារពិភពលោក។<br>• អ្នកចូលរួមបានសង្កត់ធ្ងន់ថាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យតម្លៃធនាគារពិភពលោកថាជាធនាគារចំណេះដឹង។ ការកៀរគរជំនួយឥតសំណង/ការប្រើអានុភាពធនធានឱ្យមានប្រសិទ្ធភាពគឺជាការមានសារៈសំខាន់ ហើយត្រូវបានឆ្លុះបញ្ចាំងនៅក្នុង CPF។ ដូច្នេះធនាគារពិភពលោកគួរតែធ្វើផែនការមិនគ្រាន់តែសម្រាប់គម្រោងគាំទ្រដោយសមាគមអភិវឌ្ឍអន្តរជាតិ (IDA) ប៉ុណ្ណោះទេ ប៉ុន្តែគួរធ្វើផែនការសម្រាប់នាំមកនូវជំនួយឥតសំណងបន្ថែម ដើម្បីជួយជួយអភិវឌ្ឍសមត្ថភាពបន្ថែមទៀតនាពេលអនាគត។ |